នស/រកត/០៧០០/១៣៥

# ព្រះរាជក្រឹត្យ

## ស្តីពីលក្ខន្តិកៈដោយឡែក

## នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល

## យើង

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០០។

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ **ឃ** ដូចបានចែងក្នុងមាត្រា៦ នៃ ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា ២.-**

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ដែលជាកម្មវត្ថុនៃលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលនេះ ស្ថិតនៅក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដែលប្រមូលផ្តុំមន្ត្រីរាជការធ្វើការងាររដ្ឋបាល សំរាប់បណ្តាក្រសួង-ស្ថាប័ននានា។ ឯការវិវត្តន៍របស់ភ្នាក់ងារម្នាក់ៗ គឺស្ថិតនៅក្រោមក្រសួង-ស្ថាប័នសាមី។

មិនត្រូវបានអនុញ្ញាតឱ្យបង្កើតក្របខ័ណ្ឌ សំរាប់ធ្វើការងារភ្នាក់ងាររដ្ឋបាលផ្សេងពីក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលឡើយ លើកលែងតែក្រសួងមហាផ្ទៃ។

**មាត្រា ៣.-**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលមានឧបនិស្ស័យសំរាប់បំពេញមុខតំណែងក្នុងកិច្ចការប្រតិបត្តិនៅក្នុងអង្គភាពរដ្ឋបាលកណ្តាល ខេត្ត-ក្រុង ហើយនិងក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលផងដែរ។

## ជំពូកទី ២

## ឋានន្តរស័ក្តិនៃក្របខ័ណ្ឌ

**មាត្រា ៤.-**

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល មាន ៣ ឋានន្តរស័ក្តិ ៖

- នាយភ្នាក់ងាររដ្ឋបាល មាន ០៦ ថ្នាក់
- ភ្នាក់ងាររដ្ឋបាលដើមខ្សែ មាន ១០ ថ្នាក់
- ភ្នាក់ងាររដ្ឋបាល មាន ១៤ ថ្នាក់។

## ជំពូកទី ៣

## ការជ្រើសរើស

**មាត្រា ៥.-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែង ដែលរៀបចំឡើងដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។ ចំនួនតំណែងក្នុងការជ្រើសរើស ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ៦.-**

ការប្រឡងប្រជែងជ្រើសរើស ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុយ៉ាងច្រើន ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។ អាយុនេះអាចរំកិលពី ២៥ឆ្នាំឡើងដល់ ៣០ឆ្នាំ ស្របតាមមាត្រា ១១ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

## ជំពូកទី ៤

## កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៧.-**

បេក្ខជនដែលត្រូវបានជ្រើសរើស ចាំបាច់ត្រូវឆ្លងកាត់រយៈពេលធ្វើកម្មសិក្សាមួយ ដែលប្រព្រឹត្តទៅស្របតាមបទប្បញ្ញត្តិមាត្រា ១៦ និង មាត្រាបន្តបន្ទាប់ នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បងមន្ត្រីនេះត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិភ្នាក់ងារឬក្នុងករណីចាំបាច់អាច

ត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម១២ ខែ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការធ្វើកម្មសិក្សាបន្ថែមនេះ ត្រូវបានលុបឈ្មោះចោល។ ករណីខាងលើនេះ ត្រូវសំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តាមសំណើរបស់ក្រសួងស្ថាប័នសាមី ដោយបញ្ជាក់នូវមូលហេតុ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ខែ ក្រោយការបញ្ចប់កម្មសិក្សា។ ការតែងតាំងជាភ្នាក់ងាររដ្ឋបាលកម្មសិក្សានិងការតែងតាំងស៊ប់ក្នុងឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ៨.-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិមួយរួចមក ភ្នាក់ងាររដ្ឋបាលទាំងនេះ ត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរមួយ ដែលស្របជាមួយឋានន្តរស័ក្តិរបស់ខ្លួនដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងស្ថាប័នសាមី តាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រមចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ៩.-**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា២០ និងមាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូតពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោមនេះ៖

- គោរពវិន័យការងារបានត្រឹមត្រូវ
- សម្រេចបានល្អនូវភារកិច្ចដែលប្រគល់អោយ
- មានសីលធម៌ល្អ។

ការឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ ក្នុងវេនអតីតភាព។

**មាត្រា ១០.-**

គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិ ត្រូវតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តឱ្យបានស្របជាមួយចំនួនតំណែងដែលមានទំនេរ នៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬតាមរយៈការប្រឡងប្រជែង ដោយរក្សាគោលការណ៍គិតជាភាគរយ៖

- ឋានន្តរស័ក្តិនាយភ្នាក់ងាររដ្ឋបាល = ៥ ភាគរយ
- ឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ = ២៥ ភាគរយ
- ឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល = ៧០ ភាគរយ

ការតម្លើងថ្នាក់ និងតម្លើងឋានន្តរស័ក្តិ ត្រូវសំរេចតាមប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ១១.-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ១១ នៃឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាល ។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិនាយភ្នាក់ងាររដ្ឋបាល គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរស័ក្តិភ្នាក់ងាររដ្ឋបាលដើមខ្សែ ។

**មាត្រា ១២.-**

សន្ទស្សន៍សម្រាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល និងតម្លៃឯកតានៃសន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៣.-**

មន្ត្រីនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវដាក់ឱ្យចូលនិវត្តន៍ពេលដល់អាយុ ៥៥ ឆ្នាំ ។

ចំពោះការដាក់ឱ្យចូលនិវត្តន៍ សំរេចដោយប្រកាសរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ១៤.-**

ចំនួនដំបូងនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌនៅរដ្ឋបាលកណ្តាល និង ខេត្ត ក្រុង ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

រាល់បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦.-**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**ហត្ថលេខា**

**ពេជ្រ ប៊ុនធិន**

លេខៈ ១៤៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និងត្រា**

**ណាឌី តាន់**